# តុលាការចោទអ្នកដាក់គ្រាប់បំផ្ទុះពីបទភេរវកម្មនិងប្រើប្រាស់អាវុធគ្រឿងផ្ទុះ

ដោយៈ សុវណ្ណារិទ្ធ

Court press charge on suspects for terrorism and using man-made bombs. Voice of Khmer Youth. 08/02/07

តុលាការក្រុងភ្នំពេញ បានសម្រេចចោទប្រកាន់ បុរសខ្មែរកម្ពុជាក្រោម២នាក់ ដែលពាក់ព័ន្ធទៅនឹងការដាក់គ្រាប់បំផ្ទុះ ពីបទបង្កភេរវកម្ម និងប្រើប្រាស់អាវុធគ្រឿងផ្ទុះ។ នេះបើតាមការអះអាងរបស់លោក*សុខ វឿន* ព្រះរាជអាជ្ញារង តុលាការក្រុងភ្នំពេញ បន្ទាប់ពីសមត្ថកិច្ច បញ្ជូនបុរសទាំង២នាក់ គឺ*គីម គឿន* និង*ស៊ីន ថាន* ទៅព្រៃសរួចមក។សហគមន៍ខ្មែរកម្ពុជាក្រោមនៅក្រុងភ្នំពេញ ដាក់មន្ទិលសង្ស័យ ចំពោះការចាប់ខ្លួនបុរសខ្មែរកម្ពុជាក្រោម ដែលពាក់ព័ន្ធនឹងការបំផ្ទុះគ្រាប់នេះ ។ យ៉ាងណាក៏ដោយ សង្គមស៊ីវិល សុំឱ្យតុលាការ ចាត់ការរឿងនេះឱ្យបានសមស្របទៅតាមផ្លូវច្បាប់ ។

បុរស២នាក់ ដែលក្រសួងមហាផ្ទៃ យកមកបង្ហាញមុខក្នុងសន្និសីទកាសែត កាលពីល្ងាចថ្ងៃអង្គារ មានឈ្មោះ*គីម គឿន* និង*ស៊ីន ថាន* ដែលបុរសទាំង២នាក់នេះ អះអាងថា ពួកគេមានការពាក់ព័ន្ធចំពោះការបំផ្ទុះគ្រាប់នៅស្តូបយួននោះ។ តុលាការក្រុងភ្នំពេញ បានចោទប្រកាន់បុរសទាំង ២នាក់ ហើយសម្រេចឃុំខ្លួន នៅពន្ធនាគារព្រៃស ទៅតាមអ្វីដែលបុរសទាំង ២នាក់នេះបានសារភាព ។ក្នុងនោះ ការចោទប្រកាន់ អំពីការបង្កភេរវកម្ម និងការប្រើប្រាស់អាវុធគ្រឿងផ្ទុះ គឺជាមូលហេតុ ដែលនាំឱ្យតុលាការ សម្រេចធ្វើការចោទប្រកាន់ និងនាំដល់ការឃុំខ្លួននៅពន្ធនាគារ ។

លោក*ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម បានសំដែង នូវមន្ទិលសង្ស័យជាច្រើន ចំពោះការចាប់ខ្លួន បុរសខ្មែរកម្ពុជាក្រោមទាំងនេះ ។ លោកបានបន្ថែមថា ការចាប់ខ្លួនដ៏លឿនរហ័សរបស់សមត្ថកិច្ច តាមរយៈគំនូព្រាងនោះ ធ្វើឱ្យមានការសង្ស័យជាខ្លាំង ។ បើទោះជាយ៉ាងណាក៏ដោយ នោះគ្រាន់តែជាមន្ទិលសង្ស័យមួយ មិនមែន ជាការបដិសេធទាំងស្រុង ចំពោះការខិតខំ របស់សមត្ថកិច្ច ដែលឈាន ដល់ការចាប់ខ្លួនជនសង្ស័យនោះឡើយ ។ លោកបន្ថែមថា តុលាការត្រូវធ្វើទៅតាមនីតិវិធី ចំពោះអ្វីដែលបានកើតឡើងទៅលើបុរសទាំង២នាក់នោះ បើទោះបីជា សហគមន៍ខ្មែរកម្ពុជាក្រោម មានមន្ទិលសង្ស័យយ៉ាងណាក៏ដោយ ។ នោះគ្រាន់តែជាមន្ទិលសង្ស័យ របស់បុគ្គលម្នាក់ ប៉ុន្តែ មិនមែនជាការសង្ស័យសម្រាប់ខ្មែរកម្ពុជាក្រោមទាំងអស់ នោះឡើយ ។ វាជារឿងរ៉ាវបុគ្គល ។

មន្ត្រីក្រសួងមហាផ្ទៃនិយាយថា ការចាប់ខ្លួនខ្មែរកម្ពុជាក្រោមនេះ គឺជារឿងបុគ្គលប៉ុណ្ណោះហើយ មិនពាក់ព័ន្ធ ចំពោះខ្មែរកម្ពុជាក្រោមដទៃទៀតទេ។ ផ្ទុយទៅវិញ ខ្មែរកម្ពុជាក្រោមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ប្រកបរបររកស៊ីសព្វថ្ងៃនេះ ជាមនុស្សស្លូតត្រង់ ហើយមិនប្រព្រឹត្តអំពើផ្តេសផ្តាស នាំឱ្យប៉ះពាល់ដល់សន្តិសុខសង្គមទេ។

លោកស្រី*ពុង ឈីវកេក* នាយិកា អង្គការសិទ្ធិមនុស្សលីកាដូ ដែលកំពុងតាមដានរឿងនេះ បានបញ្ចេញប្រតិកម្មថា តុលាការត្រូវចាត់ការរឿងនេះ ឱ្យបានត្រឹមត្រូវទៅតាមច្បាប់។ លោកស្រីបានអះអាងថា នោះគឺជារឿងរ៉ាវរបស់បុគ្គល មិនពាក់ព័ន្ធចំពោះខ្មែរកម្ពុជាក្រោមដទៃទៀតទេ ។ ទោះជាយ៉ាងណាក៏ដោយ តុលាការ ត្រូវចាត់ការរឿងនេះយ៉ាងណា កុំឱ្យពាក់ព័ន្ធទៅនឹងរឿងនយោបាយ ដើម្បីធានាឱ្យបាននូវការកាត់ទោស ប្រកបដោយភាពយុត្តិធម៌សម្រាប់ជនជាប់ចោទ ។

គួរបញ្ជាក់ថា កាលពីព្រឹកព្រលឹមថ្ងៃអាទិត្យ មានករណីបំផ្ទុះគ្រាប់មួយ បានកើតឡើងនៅលើស្តូបយួនមុខវត្តបុទុមវត្តី ។ សមត្ថកិច្ច ចាប់បានជនសង្ស័យ ២រូបនៅថ្ងៃច័ន្ទ ហើយក៏បានបង្ហាញមុខ នៅក្នុងសន្និសីទកាសែតមួយ កាលពីល្ងាចថ្ងៃអង្គារ ។បុរស២នាក់ ដែលត្រូវចាប់ខ្លួន សារភាពអំពីសកម្មភាពរបស់ពួកគេ ដែលដាក់គ្រាប់បំផ្ទុះនៅស្តូបនោះ។ បុរសទាំងនេះ ពាក់ព័ន្ធជាមួយនឹងខ្មែរកម្ពុជាក្រោម។ មជ្ឈដ្ឋាននានានិយាយថា ការចាប់ខ្លួននេះហាក់ដូចជាបង្កប់នូវអាថិកំបាំង ៕